ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២១៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៤១ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/៣៤១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌគ្រូបង្រៀនកម្រិតបឋម
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១៧ ស្តីពីការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ



គេហទំព័រ ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រង និងការផ្តល់សេវាអប់រំ យុវជន និងកីឡាប្រកបដោយប្រសិទ្ធភាព គុណភាព គណនេយ្យភាព តម្លាភាព បរិយាប័ន្ន និងសមធម៌សង្គម តាមរយៈការបង្ហិតការសម្រេចចិត្ត ខ្សែគណនេយ្យភាព និងការទទួលខុសត្រូវក្នុងការគ្រប់គ្រង និងការផ្តល់សេវាទាំងនេះទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌទូទាំងប្រទេស។

**មាត្រា ២.-**

វាក្យស័ព្ទដែលប្រើក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ៖

- **មុខងារ** សំដៅដល់អំពើ ឬសកម្មភាពដែលរាប់បញ្ចូលទាំងសកម្មភាពផ្តល់សេវាសាធារណៈ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយផ្សេងទៀត។
- **ការផ្ទេរមុខងារ** សំដៅដល់ការប្រគល់មុខងារ ឬការធ្វើប្រតិភូកម្មមុខងារ។
- **ការប្រគល់មុខងារ** សំដៅដល់ការផ្ទេរភាពជាម្ចាស់នៃមុខងារ ការទទួលខុសត្រូវ អំណាច និងឆន្ទានុសិទ្ធិទាំងអស់ដែលចាំបាច់ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារ។
- **ការធ្វើប្រតិភូកម្មមុខងារ** សំដៅដល់ការផ្ទេរនូវមុខងារ ការទទួលខុសត្រូវ អំណាច និងឆន្ទានុសិទ្ធិ ដើម្បីគ្រប់គ្រងនិងអនុវត្តមុខងារក្នុងនាមក្រសួង ស្ថាប័នដែលធ្វើប្រតិភូកម្ម ដោយផ្អែកតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។ ក្រសួង ស្ថាប័នដែលបានធ្វើប្រតិភូកម្មនៅតែរក្សាភាពជាម្ចាស់លើកិច្ចការដែលបានធ្វើប្រតិភូកម្ម។
- **ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌ** សំដៅដល់ការផ្តល់ធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់ និងប្រតិភូកម្មជូនដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្របតាមលក្ខខណ្ឌបច្ចេកទេស គោលការណ៍ណែនាំក្នុងការអនុវត្តមុខងារ ស្តង់ដានៃការផ្តល់សេវា លក្ខណៈបច្ចេកទេសនៃសម្ភារៈដែលបានផ្គត់ផ្គង់ កម្មវិធីការងារ យន្តការរបាយការណ៍ និងលក្ខខណ្ឌផ្សេងៗឆ្លើយតបនឹងលទ្ធផលរំពឹងទុក សូចនាករ គោលនយោបាយ និងយុទ្ធសាស្ត្រវិស័យអប់រំ។
- **ការគាំទ្រផ្នែករដ្ឋបាល** សំដៅដល់ការជួយសម្របសម្រួល គ្រប់គ្រង ចាត់ចែងប្រតិបត្តិការគាំទ្រដល់ការអនុវត្តសកម្មភាពនានានៃមុខងារអប់រំ យុវជន និងកីឡាដែលបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដូចមានកំណត់ក្នុងមាត្រា៤ និងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។
- **បុគ្គលិកអប់រំ** សំដៅដល់បុគ្គលិកអប់រំទាំងអស់ដែលត្រូវបានផ្ទេរទៅស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមានទាំងបុគ្គលិកបម្រើការងារនៅការិយាល័យអប់រំ យុវជន និងកីឡា និងបុគ្គលិកបម្រើការងារនៅគ្រឹះស្ថានសិក្សាសាធារណៈនានាដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## ជំពូកទី២

## ការផ្ទេរមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡា

**មាត្រា ៣.-**

ប្រគល់មុខងារក្នុងវិស័យអប់រំចំនួន៣ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមាន៖

១. មុខងារគ្រប់គ្រងការអប់រំកុមារតូច

២. មុខងារគ្រប់គ្រងការអប់រំបឋមសិក្សា

៣. មុខងារគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ។

មុខងាររង និងសកម្មភាពជាក់លាក់សម្រាប់មុខងារនីមួយៗខាងលើត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

ចំពោះរដ្ឋបាលក្រុង ស្រុកទាំង១៤ក្នុងខេត្តបាត់ដំបងត្រូវបន្តគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារដែលបានប្រគល់ទាំង៣ខាងលើនេះ តាមស្មារតីនៃអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង និងអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារនិងរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក និងអនុក្រឹត្យនេះ។

**មាត្រា ៤.-**

បន្តធ្វើប្រតិភូកម្មមុខងារគាំទ្រផ្នែករដ្ឋបាលក្នុងវិស័យអប់រំ យុវជន និងកីឡាចំនួន៣ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ រួមមាន៖

១. មុខងារគាំទ្រផ្នែករដ្ឋបាលដល់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ

២. មុខងារគាំទ្រផ្នែករដ្ឋបាលដល់ការងារអភិវឌ្ឍយុវជន

៣. មុខងារគាំទ្រផ្នែករដ្ឋបាលដល់ការងារអប់រំកាយ និងកីឡា។

មុខងាររង និងសកម្មភាពជាក់លាក់សម្រាប់មុខងារនីមួយៗខាងលើត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

**មាត្រា ៥.-**

គោលការណ៍ បែបបទ និងនីតិវិធីសម្រាប់អនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌដូចមានចែងក្នុងមាត្រា៣ និងមាត្រា៤នៃអនុក្រឹត្យនេះត្រូវកំណត់ដោយសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្រោមការសម្របសម្រួលដោយ គ.ជ.អ.ប. ស្របតាមច្បាប់ គោលនយោបាយ គោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៣
## ការផ្ទេរធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ

**មាត្រា ៦.-**

ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់អនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់តាមអនុក្រឹត្យនេះ គឺជាធនធានមានភ្ជាប់លក្ខខណ្ឌ។

ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់ការិយាល័យអប់រំ យុវជន និងកីឡា ដើម្បីគាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មតាមអនុក្រឹត្យនេះ គឺជាធនធានមានភ្ជាប់លក្ខខណ្ឌ។

តេឡេក្រាម ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

គ.ជ.អ.ប.ដឹកនាំសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីកំណត់អំពីទំហំធនធានហិរញ្ញវត្ថុ លក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងលក្ខខណ្ឌផ្សេងៗទៀតដែលត្រូវផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់សម្រាប់អនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់ និងសម្រាប់គាំទ្រផ្នែករដ្ឋបាលដល់ការអនុវត្តមុខងារដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មតាមអនុក្រឹត្យនេះ។

លក្ខខណ្ឌហិរញ្ញវត្ថុ លក្ខខណ្ឌបច្ចេកទេស និងលក្ខខណ្ឌផ្សេងៗទៀតនៃការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌខាងលើនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា ៧.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវរៀបចំ និងផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់អនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មដូចមានកំណត់ក្នុងមាត្រា៣ និងមាត្រា៤នៃអនុក្រឹត្យនេះ ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៨.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗត្រូវរៀបចំគម្រោងថវិកា និងអនុវត្តថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់ និងបានធ្វើប្រតិភូកម្ម ស្របតាមគោលការណ៍ និងនីតិវិធីជាធរមាន។

រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗត្រូវគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌដែលបានផ្ទេរឱ្យសម្រាប់អនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មតាមអនុក្រឹត្យនេះ។

រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗអាចប្រើប្រាស់ធនធានគ្មានភ្ជាប់លក្ខខណ្ឌ និងធនធានដែលកៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀតសម្រាប់គាំទ្រដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់ និងបានធ្វើប្រតិភូកម្ម។

**មាត្រា ៩.-**

គ.ជ.អ.ប. ដឹកនាំសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីកំណត់និងផ្ទេរទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌសម្រាប់គាំទ្រការអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់និងបានធ្វើប្រតិភូកម្ម ស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ១០.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋដែលបានផ្ទេរឱ្យស្របតាមច្បាប់ គោលនយោបាយ គោលការណ៍ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៤
## ការផ្ទេរធនធានមនុស្ស

**មាត្រា ១១.-**

ក្រោមការសម្របសម្រួលរបស់ គ.ជ.អ.ប. ក្រសួងអប់រំ យុវជន និងកីឡា ត្រូវសហការជាមួយក្រសួងមុខងារសាធារណៈ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីកំណត់ និងផ្ទេរបុគ្គលិកអប់រំដែលកំពុងបម្រើការងារនៅតាមគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗស្របតាមបែបបទនិងនីតិវិធីជាធរមាន។

**មាត្រា ១២.-**

បុគ្គលិកអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវមានលក្ខខណ្ឌការងារ បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗមិនទាបជាងលក្ខខណ្ឌការងារ បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗដែលបុគ្គលិកទាំងនោះធ្លាប់បានទទួលមុនការផ្ទេរ។

**មាត្រា ១៣.-**

ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិកអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវអនុលោមតាមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌគ្រូបង្រៀនកម្រិតបឋម កម្រិតមូលដ្ឋាន និងកម្រិតឧត្តម ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន។

ការផ្លាស់ប្តូរទីកន្លែងបម្រើការងារ និងការផ្ទេរក្របខណ្ឌគ្រូបង្រៀន ត្រូវអនុវត្តតាមគោលនយោបាយ គោលការណ៍ លិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា និងគោលការណ៍ បែបបទ នីតិវិធីពាក់ព័ន្ធជាធរមាន។

## ជំពូកទី៥
## រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងគណនេយ្យភាព របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

### ផ្នែកទី១
### រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍

**មាត្រា ១៤.-**

ត្រូវបានធ្វើសមាហរណកម្មគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ចូលទៅក្នុងរចនាសម្ព័ន្ធនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌសាមីនីមួយៗ។

មុខតំណែងនានានៃរចនាសម្ព័ន្ធគ្រប់គ្រងបច្ចុប្បន្នរបស់គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ដែលត្រូវធ្វើសមាហរណកម្មមកក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវរក្សាកម្រិត និងឋានៈដដែល។



គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យអប់រំ យុវជន និងកីឡាដែលជាសេនាធិការឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**មាត្រា ១៥.-**

គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈត្រូវដឹកនាំដោយនាយកមួយ(០១)រូប និងមាននាយករងមួយចំនួនស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការតែងតាំង និងការបញ្ចប់មុខតំណែងនាយក នាយករងនៃគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងនាយក នាយករងនៃគ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវអនុវត្តតាមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌគ្រូបង្រៀនកម្រិតបឋម កម្រិតមូលដ្ឋាន និងកម្រិតឧត្តម ព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន។

**មាត្រា ១៦.-**

មជ្ឈមណ្ឌលសិក្សាសហគមន៍ត្រូវគ្រប់គ្រងដោយគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ដែលត្រូវតែងតាំង និងផ្លាស់ប្តូរតាមគោលការណ៍ នីតិវិធី និងបែបបទជាធរមាន។

**មាត្រា ១៧.-**

គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈមានតួនាទីគ្រប់គ្រង និងផ្តល់សេវាអប់រំកុមារតូច និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន
- គ្រប់គ្រង និងប្រើប្រាស់បុគ្គលិកអប់រំមត្តេយ្យសិក្សា
- គ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋរបស់សាលារៀន
- គ្រប់គ្រងសំណង់អគារ សាងសង់ និងជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធក្នុងសាលារៀន
- គ្រប់គ្រងសិស្សមត្តេយ្យសិក្សា
- បង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀនដោយមានការចូលរួមពីតំណាងអាជ្ញាធរមូលដ្ឋាន និងមាតាបិតា
- គ្រប់គ្រងកម្មវិធីគាំទ្រការអប់រំកុមារតូច
- អភិវឌ្ឍវិស័យអប់រំដោយសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍនានា
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពីអភិបាលក្រុង ស្រុក ខណ្ឌ។

**មាត្រា ១៨.-**

គ្រឹះស្ថានបឋមសិក្សាសាធារណៈមានតួនាទីគ្រប់គ្រង និងផ្តល់សេវាអប់រំកម្រិតបឋមសិក្សា និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន

- គ្រប់គ្រង និងប្រើប្រាស់បុគ្គលិកអប់រំបឋមសិក្សា
- គ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋរបស់សាលារៀន
- គ្រប់គ្រង ចាត់ចែង និងថែទាំសៀវភៅសិក្សាគោល
- គ្រប់គ្រងសំណង់អគារ សាងសង់ និងជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធក្នុងសាលារៀន
- គ្រប់គ្រងសិស្សសាលាបឋមសិក្សា
- បង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការគ្រប់គ្រងថ្នាក់រៀនដោយមានការចូលរួមពីតំណាងអាជ្ញាធរមូលដ្ឋាន និងមាតាបិតា
- គ្រប់គ្រងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន និងគណៈកម្មការអភិវឌ្ឍន៍កម្រងសាលារៀន
- គ្រប់គ្រងកម្មវិធីគាំទ្រការអប់រំបឋមសិក្សា
- គ្រប់គ្រងការងារអប់រំកាយ និងកីឡាក្នុងសាលារៀន
- អភិវឌ្ឍវិស័យអប់រំដោយសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍនានា
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពីអភិបាលក្រុង ស្រុក ខណ្ឌ។

**មាត្រា ១៩.-**

មជ្ឈមណ្ឌលសិក្សាសហគមន៍មានតួនាទីគ្រប់គ្រង និងផ្តល់សេវាអប់រំក្រៅប្រព័ន្ធ និងមានភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍មជ្ឈមណ្ឌលសិក្សាសហគមន៍ និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍
- ប្រែក្លាយមជ្ឈមណ្ឌលសិក្សាសហគមន៍មួយចំនួនឱ្យក្លាយជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត
- គ្រប់គ្រង និងប្រើប្រាស់គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ
- គ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍
- គ្រប់គ្រង ចាត់ចែង និងថែទាំសៀវភៅសិក្សាគោល
- គ្រប់គ្រងសំណង់អគារ សាងសង់ និងជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍
- គ្រប់គ្រងអ្នកសិក្សាក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ
- គ្រប់គ្រងកម្មវិធីគាំទ្រការអប់រំក្រៅប្រព័ន្ធ
- អភិវឌ្ឍវិស័យអប់រំដោយសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍនានា
- បំពេញការងារផ្សេងៗទៀតតាមការប្រគល់ភារកិច្ចពីអភិបាលក្រុង ស្រុក ខណ្ឌ។



តេឡេក្រាម ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

**មាត្រា ២០.-**

ការបង្កើត ការបិទ ការរំលាយបញ្ចូលគ្នា ការបំបែក ការប្រែក្លាយ និងការគ្រប់គ្រងគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈនិងឯកជន គ្រឹះស្ថានបឋមសិក្សាសាធារណៈនិងឯកជន និងការបង្កើតនិងការគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ ត្រូវអនុវត្តតាមបទប្បញ្ញត្តិ និងគោលការណ៍នានាដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា។

គ្រឹះស្ថានសិក្សាសាធារណៈមានស្វ័យភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រងរដ្ឋបាល ការបង្រៀន និងការរៀន ការកៀរគរធនធាន និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋ និងការវាយតម្លៃគុណផលបុគ្គលិកអប់រំ។ ការគ្រប់គ្រង ការប្រើប្រាស់ធនធានហិរញ្ញវត្ថុត្រូវអនុវត្តតាមគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀន និងអនុលោមតាមគោលការណ៍ណែនាំ បែបបទ និងនីតិវិធីជាធរមាន។

## ផ្នែកទី២
## តួនាទី ភារកិច្ច និងការទទួលខុសត្រូវ
## របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ

**មាត្រា ២១.-**

រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗត្រូវទទួលខុសត្រូវលើការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មដូចមានចែងក្នុងមាត្រា៣ និងមាត្រា៤នៃអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងស្តង់ដាអប់រំ។

រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានភារកិច្ចដូចខាងក្រោម ៖

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំសម្រាប់អនុវត្តមុខងារអប់រំ យុវជន និងកីឡាដើម្បីដាក់បញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារអប់រំ យុវជន និងកីឡាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ធានាបាននូវគុណភាពស្របតាមស្តង់ដាអប់រំដែលបានកំណត់ដោយធានានូវស្វ័យភាពរបស់គ្រឹះស្ថានសិក្សាសាធារណៈ
- គ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋ និងបុគ្គលិកដែលបានផ្ទេរសម្រាប់អនុវត្តមុខងារអប់រំ យុវជន និងកីឡាឱ្យមានប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពស្របតាមគោលការណ៍ បែបបទ និងនីតិវិធីដែលបានកំណត់ ដោយធានានូវស្វ័យភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានសិក្សាសាធារណៈ
- សហការជាមួយស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាដើម្បីគាំទ្រដល់ការអនុវត្តមុខងារអប់រំ យុវជន និងកីឡា
- ចូលរួម គាំទ្រ និងសហការជាមួយមន្ទីរអប់រំ យុវជន និងកីឡា និងក្រសួងអប់រំ យុវជន និងកីឡា

ក្នុងការអនុវត្តមុខងារផ្សេងទៀតដែលស្ថិតក្នុងសមត្ថកិច្ចរបស់មន្ទីរ ឬក្រសួងអប់រំ យុវជន និងកីឡា

- អាចធ្វើប្រតិភូកម្មនូវមុខងារអប់រំ យុវជន និងកីឡាចាំបាច់មួយចំនួនទៅឱ្យរដ្ឋបាលឃុំ សង្កាត់
- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយនៅតាមគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ គ្រឹះស្ថានបឋមសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍
- កៀរគរការគាំទ្រថវិកា សម្ភារ និងបច្ចេកទេសពីអ្នកពាក់ព័ន្ធនានា និងអាចប្រើប្រាស់ធនធានទាំងនោះតាមឆន្ទានុសិទ្ធិរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តមុខងារអប់រំ យុវជន និងកីឡា
- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តមុខងារអប់រំ យុវជន និងកីឡាតាមការកំណត់ជូនមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីបូកសរុបជូនក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុនៃការអនុវត្តមុខងារអប់រំ យុវជន និងកីឡាតាមការកំណត់ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបូកសរុបជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ផ្នែកទី៤
## គណនេយ្យភាព

### មាត្រា ២២.-

ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌត្រូវមានគណនេយ្យភាព និងការទទួលខុសត្រូវចំពោះរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមរយៈប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រអប់រំ ស្តង់ដាអប់រំ គោលការណ៍ និងនីតិវិធីដែលបានកំណត់ និងត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងការផ្តល់សេវាអប់រំក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

នាយកគ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ នាយកគ្រឹះស្ថានបឋមសិក្សាសាធារណៈ និងប្រធានមជ្ឈមណ្ឌលសិក្សាសហគមន៍ត្រូវមានគណនេយ្យភាព និងការទទួលខុសត្រូវចំពោះប្រធានការិយាល័យអប់រំ យុវជន និងកីឡា។

បុគ្គលិកអប់រំទាំងអស់នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រធានអង្គភាពផ្ទាល់របស់ខ្លួន និងមានគណនេយ្យភាពដោយប្រយោលចំពោះនាយករដ្ឋបាល អភិបាល គណៈអភិបាល និងក្រុមប្រឹក្សាតាមឋានានុក្រម។

## ជំពូកទី៦
## ការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ



គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

**មាត្រា ២៣.-**

គ.ជ.អ.ប. ដឹកនាំសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការប្រគល់ និងការធ្វើប្រតិភូកម្មមុខងារអប់រំ យុវជន និងកីឡា និងការផ្ទេរធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងសម្របសម្រួលផ្តល់ការគាំទ្រ ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើរដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំ យុវជន និងកីឡាទាំងនេះឱ្យមានប្រសិទ្ធភាព គុណភាព តម្លាភាព និងគណនេយ្យភាពស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រអប់រំ ស្តង់ដាអប់រំ គោលការណ៍ និងនីតិវិធីដែលបានកំណត់។

**មាត្រា ២៤.-**

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡាត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងរដ្ឋសភាលើវិស័យអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡាមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ស្តង់ដាអប់រំ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តនានា
- រៀបចំកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន និងសៀវភៅសិក្សាគោល
- កំណត់និយាមសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ស្តង់ដាអប្បបរមាសម្រាប់ផ្គត់ផ្គង់ និងការប្រើប្រាស់បុគ្គលិក
- ផ្តល់ការសាងសង់ និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធនានាសម្រាប់គ្រឹះស្ថានសិក្សាសាធារណៈ
- ផ្តល់ការគាំទ្រ និងលើកទឹកចិត្តដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបុគ្គលិកអប់រំដែលត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- ជ្រើសរើស បណ្តុះបណ្តាល បែងចែក និងរឹត្រឹតការគ្រូមត្តេយ្យសិក្សា និងគ្រូបឋមសិក្សា
- ផ្តល់ការបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌអំពីការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានប្រគល់ និងបានធ្វើប្រតិភូកម្ម
- កៀរគរធនធានពីប្រភពស្របច្បាប់នានាសម្រាប់គាំទ្រដល់កម្មវិធី ឬសកម្មភាពនានាពាក់ព័ន្ធនឹងការកែលម្អគុណភាពនៃការអប់រំ យុវជន និងកីឡា
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់ និងបានធ្វើប្រតិភូកម្ម
- វាយតម្លៃគុណភាពសេវាអប់រំ យុវជន និងកីឡាដែលបានប្រគល់ និងបានធ្វើប្រតិភូកម្ម
- អនុវត្តតួនាទី ភារកិច្ចផ្សេងទៀតស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្រសួងអប់រំ យុវជន និងកីឡាអាចធ្វើប្រតិភូកម្មជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តក្នុងការគាំទ្របច្ចេកទេស ការអភិវឌ្ឍសមត្ថភាព ការតាមដាន ការត្រួតពិនិត្យ ការវាយតម្លៃ ការធ្វើអធិការកិច្ច សវនកម្ម និងកិច្ចការផ្សេងទៀតតាមការចាំបាច់លើការអនុវត្តមុខងារអប់រំដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មទៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**មាត្រា ២៥.-**

ក្រសួងមហាផ្ទៃសម្របសម្រួល និងគាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំ យុវជន និងកីឡា និងធនធានដែលបានប្រគល់ និងបានធ្វើប្រតិភូកម្ម ព្រមទាំងសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

**មាត្រា ២៦.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសហការជាមួយក្រសួងអប់រំ យុវជន និងកីឡាក្នុងការរៀបចំនិងផ្ទេរធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ ព្រមទាំងផ្តល់ការគាំទ្រការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**មាត្រា ២៧.-**

ក្រសួងមុខងារសាធារណៈសហការជាមួយក្រសួងអប់រំ យុវជន និងកីឡាក្នុងការគាំទ្រដល់ការផ្ទេរបុគ្គលិកអប់រំកុមារតូច បុគ្គលិកអប់រំបឋមសិក្សា និងបុគ្គលិកអប់រំក្រៅប្រព័ន្ធ ព្រមទាំងផ្តល់ការគាំទ្រការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិកអប់រំដែលបានផ្ទេរទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**មាត្រា ២៨.-**

រដ្ឋបាលរាជធានី ខេត្តមានតួនាទីសម្របសម្រួលជាមួយមន្ទីរអប់រំ យុវជន និងកីឡា និងមន្ទីរ អង្គភាពពាក់ព័ន្ធនានា ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានាក្នុងការផ្តល់ការគាំទ្រដល់ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលក្រុង ស្រុក ខណ្ឌនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ជំពូកទី៧
## ក្របខណ្ឌពេលវេលានៃការអនុវត្ត

**មាត្រា ២៩.-**

គ.ជ.អ.ប. ដឹកនាំសម្របសម្រួលជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីរៀបចំផ្ទេរបេនាសម្ព័ន្ធ បុគ្គលិក ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋ និងរៀបចំនីតិវិធីសម្រាប់អនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មតាមអនុក្រឹត្យនេះ ព្រមទាំងផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធនានាអំពីខ្លឹមសារអនុក្រឹត្យនេះឱ្យបានរួចរាល់នៅមុនដំណាច់ឆ្នាំ២០២៣។

រដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗត្រូវចាប់ផ្តើមគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់ ព្រមទាំងបន្តអនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មស្របតាមមាត្រា៣ និងមាត្រា៤នៃអនុក្រឹត្យនេះចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤តទៅ។



គេហទំព័រ ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា ៣០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១១ កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ច ស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** | **រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងជាប្រធាន គ.ជ.អ.ប.**

**សម្តេចក្រឡាហោម ស ខេង** | **បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣១
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ